# **អារម្ភកថា**

នេះជាស្នាដៃមួយដំបូង ដែលក្រុមជំនុំព្រះគុណដំណឹងល្អនៃព្រះគ្រីស្តភ្នំពេញបានធ្វើការបកប្រែឯកសារពីភាសាអង់គ្លេស ដែលមានឈ្មោះថា HIGH WAY OF LIFE ដែលយើងបកជាភាសាខ្មែរថា **មាគ៌ានៃជីវិត** ។

ការបកប្រែនេះ គឺគោលបំណងរបស់យើងចង់ជួយដល់បងប្អូនទាំងអស់ជាប្រជាជនខ្មែរ ក្នុងការសិក្សាព្រះគម្ពីរ ។ សៀវភៅ**មាគ៌ានៃជីវិត** គឺបានបំភ្លឺពីការសិក្សាព្រះគម្ពីរទាំងមូល ដែលបាននិយាយដំណើររឿងពី កំណើតពិភពលោក រហូតដល់ វិវរណៈ ។ នៅក្នុងនេះផងដែរ ក្នុងសៀវភៅ**មាគ៌ានៃជីវិត**ជួយបងប្អូនអោយយល់ពីដំណើររឿងដំបូងបង្អស់ ដែលចាប់ផ្តើមឡើងនៅសួនច្បារអេដែន ហើយនឹងត្រូវបញ្ចប់នៅពេលដែលរាជាណាចក្រនៃព្រះជាម្ចាស់ត្រូវបង្កើតនៅលើផែនដី ។

**មាគ៌ានៃជីវិត** គឺជាគ្រឹះមួយសំរាប់ជួយអោយបងប្អូនសិក្សាព្រះគម្ពីរទាំងមូលងាយយល់ពីគម្រោងផែនការរបស់ព្រះជាម្ចស់ ដែលទ្រង់ធ្វើជាមួយមនុស្សពីដើមរហូតមកដល់បច្ចុប្បន្ន នឹងបន្តរហូតអនាគតកាល ។ ក្នុងការសិក្សាព្រះគម្ពីរ គឺជាការស្វែងយល់អំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលផ្តល់មកអោយមនុស្ស ដើម្បីអោយមនុស្សទទួលបានការសង្គ្រោះពីព្រះជាម្ចាស់ ។ ហេតុអ្វីបានជាមនុស្សត្រូវការទទួលការសង្គ្រោះ? ពីព្រោះតែមនុស្សមានអំពើបាប(រ៉ូម៣:២៣) ហើយផ្តល់នៃអំពើបាប គឺជាសេចក្តីស្លាប់ (រ៉ូម៦:២៣) ដូច្នេះមនុស្សត្រូវតែសុំការអត់ទោសពីព្រះជាម្ចាស់ ដើម្បីទទួលការសង្គ្រោះ ។ តើយើងធ្វើយ៉ាងមេចទើបដឹងថាព្រះជាម្ចាស់អត់ទោសអោយយើង? ចម្លើយគឺនៅក្នុងព្រះគម្ពីរ ដូច្នេះចូរអានព្រះគម្ពីរជារៀងរាល់ថ្ងៃ នោះបងប្អូននឹងថាតើយើងត្រូវធ្វើយ៉ាងណាទើបទទួលការអត់ទោសពីព្រះជាម្ចាស់ ។ ព្រះជាម្ចាស់ស្រលាញ់បងប្អូនខ្លាំងណាស់(យ៉ូហាន៣:១៦) ព្រះជាម្ចាស់មិនចង់អោយមនុស្សធ្លាក់ទៅក្នុងបឹងភ្លើងទេ ព្រះជាម្ចាស់ចង់អោយទទួលការសង្គ្រោះគ្រប់ៗគ្នា ដូច្នេះហើយបានជាទ្រង់ប្រទាននូវព្រះគម្ពីរដែលជាព្រះបន្ទូលរបស់ទ្រង់មកអោយមនុស្ស ដើម្បីឱ្យមនុស្សស្គាល់ទ្រង់ និងដឹងថាខ្លួនជាមនុស្សដែលមានអំពើបាប ខ្វះសិរីល្អពីព្រះជាម្ចាស់ ត្រូវការព្រះជាម្ចាស់អត់ទោសអោយរួចពីចំណងអំពើបាបរបស់ខ្លួន ដើម្បីអាចទទួលការសង្គ្រោះបាន ។

នៅក្នុងសៀវភៅនេះបានបង្ហាញពីសម័យកាលនីមួយៗ ដែលព្រះជាម្ចាស់ផ្តល់អោយតាមសម័យកាលរបស់មនុស្សរស់នៅលើផែនដី ។ លក្ខណៈពិសេសនៃសៀវភៅនេះ គឺលើកយកខគម្ពីរយោង ដើម្បីឱ្យបងប្អូនងាយយល់ និងអាចអោយពិចារណាទៅលើអត្ថន័យដែលបានលើកឡើងនៅមេរៀននីមួយៗនៃសៀវភៅនេះ ។

ជំនឿធ្វើអោយយើងមានអ្វីៗដែលយើងសង្ឃឹមថានឹងបាន និងធ្វើអោយស្គាល់ជាក់ច្បាស់ នូវអ្វីៗដែលយើងមើលពុំឃើញ(ហេប្រឺ១១:១) ។ បើគ្មានជំនឿ គ្មាននរណាអាចគាប់ព្រះហឫទ័យព្រះអង្គបានឡើយ(ហេប្រឺ១១:៦) ។ ជំនឿប្រៀបបាននឹងគ្រាប់ព្រួញ ហើយការសង្គ្រោះប្រៀបបាននឹងផ្ទាំងស៊ីបមួយ ដើម្បីឱ្យយើងអាចទទួលការសង្គ្រោះបានលុះត្រាតែយើងប្រើគ្រាប់ព្រួញរបស់យើងចោលអោយត្រូវគោលដៅ ។

**សូមព្រះជាម្ចាស់ប្រទានពរបងប្អូន**

## <u>សូមថ្លែងអំណរគុណដល់៖</u>

### ក្រុមនិស្សិត៖

លោក : ម៉ុក ង៉ួន    កញ្ញា : ពិន ចន្ថា

លោក : សន ស្រួច

កញ្ញា : ម៉ឹក សុផល

លោក : ឡាយ ស៊ីនិត    កញ្ញា : ញាញ់ ចន្ថា

លោក : សន ស្រួច    កញ្ញា : ម៉ឹក សុផល

លោក : ហួ ពន្លក    កញ្ញា : អន រិទ្ធី

លោក : ម៉េង សេងហាក់    កញ្ញា : ស៊ីវ សុភា

### ក្រុមបេសកជន

លោកគ្រូ :អារីយ៉េល ម៉ាហ៊ីលូម (Ariel Mahilum)

អ្នកគ្រូ :ម៉ៃរ៉ា អូម៉ិចទីន (Myra Omictin)

ដែលបានជួយបកប្រែ កែសម្រួល និងរក្សាអត្ថន័យដើម!

(បកប្រែពីសៀវភៅ HIGHWAY of LIFE)

បើមានចំណាប់អារម្មណ៍ក្នុងការសិក្សាមេរៀនបន្ទាប់

សូមទំនាក់ទំនង៖

អង្គការ TCMកម្ពុជា

ក្រុមជំនុំព្រះគុណដំណឹងល្អនៃព្រះគ្រីស្ទភ្នំពេញ

Email: tcmcambodia@yahoo.com

ចាប់ផ្តើមបកប្រែ : ខែ សីហា ឆ្នាំ ២០០៨

បោះពុម្ពលើកទី ១ : ខែ កុម្ភៈ ឆ្នាំ ២០១២